ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្នាក់ការក្រសួងយុត្តិធម៌
លេខ.១២៨.អយក.យក/១១

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែ ៥ ឆ្នាំ ២០១១

ប្រកាស
ស្តីពី
អត្រាការប្រាក់ដែលត្រូវបានកម្រិត

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៩៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
-បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

សម្រេច

<u>ប្រការ ១.-</u>

អត្រាការប្រាក់ដែលត្រូវបានកម្រិតដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវបានកម្រិត ជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពី ១៨% (ដប់ប្រាំបីភាគរយ) ក្នុង ១ (មួយ) ឆ្នាំ។

<u>ប្រការ ២.-</u>

អត្រាការប្រាក់ ដែលព្រមព្រៀងជាមុនក្នុងការសងសំណងក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានតម្លៃជាប្រាក់ ដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូ

បានកម្រិត ជាអាទ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពីចំនួន ១,៥ (មួយក្បៀសប្រាំ) ដង នៃអត្រាការប្រាក់ដែលបានកំណត់ក្នុងប្រការ ១ ខាងលើ។

ប្រការ ៣.-

ប្រកាសនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ

អ្នកទទួលបន្ទុក